# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ


MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


លេខ...០២៦.....សហវ. អគត

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរំលឹកការបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១១

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនលោក លោកស្រី ម្ចាស់អចលនទ្រព្យស្ថិតនៅក្នុងរដ្ឋបាលខណ្ឌនៃរាជធានី និងស្ថិតនៅក្នុងរដ្ឋបាលក្រុងនៃខេត្តនានា មេត្តាជ្រាបថា ចាប់ពីថ្ងៃជូនដំណឹងស្តីពីការអនុវត្តប្រមូលពន្ធនៅខែឧសភា ឆ្នាំ២០១១ រហូតមកទល់ពេលនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្កេតឃើញថា មានម្ចាស់អចលនទ្រព្យជាច្រើនបានអញ្ជើញមកប្រកាសបង់ពន្ធតាមសេចក្តីជូនដំណឹងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ទន្ទឹមនឹងនេះ ក៏មានម្ចាស់អចលនទ្រព្យមួយចំនួននៅមិនទាន់បានមកបំពេញកាតព្វកិច្ចបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១១នេះឡើយ ។ ការប្រមូលពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១១នេះ ត្រូវបានពន្យារពេលរហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ដោយសារពន្ធលើអចលនទ្រព្យនេះជាប្រភេទពន្ធស្វ័យប្រកាសថ្មី ទាមទារការស្វែងយល់អំពីបែបបទគណនា និងតម្លៃអចលនទ្រព្យដែលត្រូវជាប់ពន្ធផង និងដោយរយៈពេលនៃការបង់ពន្ធនេះជាន់គ្នាជាមួយនឹងថ្ងៃឈប់សំរាកបុណ្យច្រើនផង ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមរំលឹកដល់លោក លោកស្រី ជាម្ចាស់អចលនទ្រព្យទាំងអស់ ដែលពុំទាន់បានបំពេញកាតព្វកិច្ចបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១១នេះ មេត្តារួសរាន់មកប្រកាសបង់ពន្ធឱ្យបានរួសរាន់ទាន់ពេលវេលា ឱ្យបានមុនថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ជៀសវាងនូវការប្រជ្រៀតគ្នានៅថ្ងៃជិតផុតកំណត់ ដែលនាំឱ្យខកខានពុំបានបង់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រី ម្ចាស់អចលនទ្រព្យមានស្មារតីគោរពច្បាប់ និងអញ្ជើញមកប្រកាសបង់ពន្ធតាមកាលកំណត់ជាពុំខាន ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com